00531868

ឯកសារចម្លងបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
26 / 07 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

D353/2/3

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*នាមប្រជារាស្ត្រខ្មែរ និងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៦២)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
26 / 07 / 2010
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

| | |
|---|---|
| ចំពោះមុខ: | **ចៅក្រម ប្រាក់ គឹមសាន, ប្រធាន** |
| | **ចៅក្រម** Rowan DOWNING |
| | **ចៅក្រម នី យ ចុល** |
| | **ចៅក្រម** Catherine MARCHI-UHEL |
| | **ចៅក្រម ហួត វុទ្ធី** |
| កាលបរិច្ឆេទ: | ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ |

---

**សាធារណៈ(ដោយកោសលុប)**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀងធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
នី ចាន់ឌី
Mahdev MOHAN

**ជនត្រូវចោទ**
អៀង ធីរិទ្ធ

**សហមេធាវីការពារក្តីជនត្រូវចោទ**
ផាត់ ពៅសៀង
Diana ELLIS

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

00531869



Lyma NGUYEN
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Elizabeth-Joelle RABESANRATANA
Annie DELAHAIE
Philippe CANONNE
Martine JACQUIN
Fabienne TRUSSES-NAPROUS
Françoise GAUTRY
Isabelle DURAND
Christine MARTINEAU
Laure DESFORGES
Ferdinand DJAMMEN-NZEPA
ឡោ ជុនធី
ស៊ីន សុវ៉ន
សំ សុគង់
ហុង គីមសួន
គង់ ពិសី
គង់ ហេង
Silke STUDZINSKY
Olivier BAHOUGNE
Marie GUIRAUD
Partirck BAUDOUIN
ជេត វណ្ណលី
ពេជ អង្គ
Julien RIVET
Pascal AUBOIN
យុង ផានិត

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") កត់សម្គាល់ឃើញមាន "បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ស្នើឡើងដោយសហមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០"[១] ("បណ្តឹងឧទ្ធរណ៍") ដែល អៀង ធីរិទ្ធ បានប្តឹងនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ដើមបណ្តឹងឧទ្ធរណ៍បានដាក់ "សហមេធាវីការពារក្តីស្នើសុំបំពេញកិច្ចស៊ើបសួរលើសាក្សីសំខាន់ៗ"[២] ("សំណើ") ដែលនៅក្នុងនោះបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយបុគ្គល[redacted][៣]។

២. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានដាក់ "ដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី អៀង ធីរិទ្ធ"[៤] ("ដីកាសម្រេច") ដោយបានបដិសេធសំណើរបស់ដើមបណ្តឹងឧទ្ធរណ៍។ ដីកាសម្រេចនេះចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ហើយបានជូនដំណឹងដល់ដើមបណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០។ ដើមបណ្តឹងឧទ្ធរណ៍បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០[៥] ហើយបានដាក់សារណាបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០។

---

[១] បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ស្នើឡើងដោយសហមេធាវីការពារក្តីរបស់ អៀង ធីរិទុធ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០" ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០ D353/2/1 ("បណ្តឹងឧទ្ធរណ៍")។

[២] សហមេធាវីការពារក្តីស្នើសុំបំពេញកិច្ចស៊ើបសួរលើសាក្សីសំខាន់ៗ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ D352 ("សំណើ")។

[៣] សំណើ កថាខណ្ឌទី ១។

[៤] ដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ D353/1 ("ដីកា")។

[៥] សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងទៅនឹងដីកាសម្រេចសំណើសុំឱ្យបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តីអ្នកស្រី អៀង ធិរិទ្ធ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០ D353/2។



E.C.C.C ✱ C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00531871



៣. ភាគីមិនបានដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ ស្របតាមមាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តអំពី "ការដាក់ឯកសារនៅ អ.វ.ត.ក" ឡើយ[៦]។

៤. នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ ដើមបណ្តឹងឧទ្ធរណ៍ទទួលបានការជូនដំណឹងពីអង្គបុរេជំនុំជម្រះអំពីសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ[៧]។

## II. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៥. ដើមបណ្តឹងឧទ្ធរណ៍បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ស្របតាមរយៈពេលកំណត់ដូចមានចែងនៅក្នុងវិធាន៧៥(១)នៃវិធានផ្ទៃក្នុង(វិ.លើកទី៥) ហើយដើមបណ្តឹងបណ្តឹងឧទ្ធរណ៍ក៏បានដាក់សារណារបស់ខ្លួន ក្នុងរយៈពេលកំណត់ដូចមានចែងនៅក្នុងវិធាន៧៥(៣)នៃវិធានផ្ទៃក្នុងផងដែរ។

៦. អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំស្តាប់ចម្លើយបុគ្គលណាម្នាក់ ត្រូវបានចាត់ទុកថា ជាសំណើសុំបំពេញ "កិច្ចស៊ើបសួរ" ស្របតាមបទបញ្ញត្តិ នៃវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង[៨]។

៧. អង្គបុរេជំនុំជម្រះយល់ស្របជាមួយនឹងដើមបណ្តឹងឧទ្ធរណ៍[៩]ថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ខ)៖

> ជនត្រូវចោទ ឬ ជនជាប់ចោទ អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីកា ឬ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដូចខាងក្រោម៖...(ខ) ការបដិសេធពាក្យសុំឱ្យមានកិច្ចស៊ើបសួរណាមួយដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។

## III. មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ដែលបានយកមកពិចារណា

---

[៦] អ.វ.ត.ក/០១/២០០៧/វិ. លើកទី៤។

[៧] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ D353/2/2។

[៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ A190/I/20 កថាខណ្ឌទី ២១ - ២៨។

[៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៨។

## បទដ្ឋាននៃការពិនិត្យបណ្តឹងឧទ្ធរណ៍ឡើងវិញ

៨. អង្គបុរេជំនុំជម្រះសូមរំលឹកឡើងវិញថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបំពេញកិច្ចស៊ើបសួរ ជាដីកាសម្រេចដែលបានធ្វើឡើងតាមឆន្ទានុសិទ្ធិ។ ដូច្នេះ ដើម្បីអាចឱ្យអង្គបុរេជំនុំជម្រះច្រានចោលការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតបាន ដើមបណ្តឹងឧទ្ធរណ៍ ត្រូវបង្ហាញឱ្យឃើញថា ដីកាសម្រេចដែលត្រូវបានជំទាស់នោះ (i) ផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើច្បាប់ជាធរមាន (ii) ផ្អែកលើការសន្និដ្ឋាន មិនត្រឹមត្រូវទាល់តែសោះលើអង្គហេតុ និង/ឬ (iii) មានភាពអយុត្តិធម៌ និងមិនសមហេតុផលខ្លាំងដែលជាការរំលោភបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត[១០]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា មិនមែនគ្រប់កំហុសទាំងអស់នឹងនាំឱ្យខ្លួនបដិសេធចោលសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតឡើយ វាទាល់តែកំហុសនោះមានអានុភាពយ៉ាងខ្លាំងលើការអនុវត្តឆន្ទានុសិទ្ធិ ដែលជាហេតុនាំឱ្យភាគីប្តឹងឧទ្ធរណ៍។

៩. ដើមបណ្តឹងឧទ្ធរណ៍បានធ្វើការតវ៉ាលើដីកាសម្រេច ដោយ“ជាគោលការណ៍”[១១] ផ្អែកលើបទដ្ឋានទីមួយនៃការពិនិត្យបណ្តឹងឧទ្ធរណ៍ឡើងវិញ ពោលគឺ ដីកាសម្រេចនោះ បានផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើច្បាប់ជាធរមាន[១២]។ បើទោះជាបែបនេះក្តី អង្គបុរេជំនុំជម្រះនឹងធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ ដោយផ្អែកលើបទដ្ឋានចំនួនបីសម្រាប់ការពិនិត្យបណ្តឹងឧទ្ធរណ៍ឡើងវិញ។

## សំណើរបស់ដើមបណ្តឹងឧទ្ធរណ៍

១០. យោងតាមសំណើរបស់ខ្លួន ដើមបណ្តឹងឧទ្ធរណ៍មានបំណងស្នើសុំឱ្យធ្វើការស្តាប់ចម្លើយ [redacted] ដែលបានកំណត់ឈ្មោះ។ ដើមបណ្តឹងឧទ្ធរណ៍លើកឡើងថា៖

> [១៥] មេធាវីការពារក្តីយល់ឃើញថា មនុស្ស [redacted] ខាងលើនេះពិតជាមានសមត្ថភាពផ្តល់ឱ្យ ក.ស.ច.ស នូវព័ត៌មានពាក់ព័ន្ធអំពីក្រសួង ព្រមទាំងតួនាទី និងការទទួលខុសត្រូវរបស់ជនត្រូវចោទ។

---

[១០] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ D164/4/13 កថាខណ្ឌទី ២៥ - ២៧។

[១១] សំណើ កថាខណ្ឌទី ៩។

[១២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៩។

ជាពិសេស មានម្នាក់ក្នុងចំណោមមនុស្សទាំងនោះ [redacted] ហើយដែលអាចផ្តល់ឱ្យ ក.ស.ច.ស នូវព័ត៌មានពាក់ព័ន្ធនឹងជនត្រូវចោទ។

[១៦]លើសពីនេះទៀតនោះ បុគ្គលម្នាក់ៗក៏អាចផ្តល់ភស្តុតាងដោះបន្ទុកផងដែរដល់ ក.ស.ច.ស ពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់ជនត្រូវចោទ នៅក្នុងក្រសួងរបស់គាត់។ មេធាវីការពារក្តីសូមទាមទារបន្ថែមទៀតថា មនុស្សទាំងនេះក៏អាចផ្តល់ការបញ្ជាក់ផ្ទៀងផ្ទាត់លើព័ត៌មានលម្អិតនៃហេតុការណ៍របស់ជនត្រូវចោទ នៅពេលដែលគាត់បានអនុវត្តតួនាទីរបស់គាត់ជារដ្ឋមន្ត្រី ដែលកើតមានក្នុងកំឡុងពេលនោះ។

[១៧] នៅក្នុងចំណុចចុងក្រោយ មេធាវីការពារក្តីសូមស្នើឱ្យ ក.ស.ច.ស ពិគ្រោះយោបល់ជាមួយនឹងមេធាវីការពារក្តីមុននឹងបំពេញកិច្ចស៊ើបសួរនេះ ដើម្បីពិភាក្សារកមធ្យោបាយ ដែលមានប្រសិទ្ធិភាពបំផុតក្នុងការស្វែងរកព័ត៌មានដែលបានស្នើសុំនេះ និងព័ត៌មានលម្អិតថែមទៀតស្តីពីសាក្សីសំខាន់ៗទាំងអស់នេះ។

១១. ក្រៅពីការផ្តល់ឈ្មោះរបស់បុគ្គលទាំងនោះ ដើមបណ្តឹងឧទ្ធរណ៍បានផ្តល់ជូនព័ត៌មានអង្គហេតុដែលបាន(ចោទប្រកាន់)តែមួយគត់អំពីបុគ្គល[redacted]នេះនៅក្នុងសំណើ ពោលគឺអំពីតួនាទីរបស់បុគ្គលទាំងនោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលរួមមាន៖

១) [redacted]ក្រោមឱវាទរបស់ក្រសួងសង្គមកិច្ច។

២) [redacted]ក្រោមឱវាទរបស់ក្រសួងសង្គមកិច្ច។

៣) [redacted] ក្រោមឱវាទរបស់ក្រសួងសង្គមកិច្ច។

៤) [redacted]នៅក្រសួងសង្គមកិច្ច។

៥) [redacted]ក្រសួងសង្គមកិច្ច។

៦) [redacted]ក្រោមឱវាទរបស់ក្រសួងសង្គមកិច្ច។

៧) [redacted] ក្រោមឱវាទរបស់ក្រសួងសង្គមកិច្ច និងធ្លាប់ជាចុងភៅផ្ទាល់របស់ជនត្រូវចោទ។

៨) [redacted]របស់ក្រសួងសង្គមកិច្ច។

៩) [redacted] ក្រោមឱវាទរបស់ក្រសួងសង្គមកិច្ច[១៣]។

## សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត

១២. ខាងក្រោមនេះជាសំអាងហេតុទាំងឡាយរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបដិសេធសំណើរបស់ដើមបណ្តឹងឧទ្ធរណ៍៖

[១៣] សំណើ កថាខណ្ឌទី ១៤។

[៣] សហចៅក្រមស៊ើបអង្កេតបានពិនិត្យមើលបញ្ជីដែលមានឈ្មោះ [redacted] ដែលបានដាក់ភ្ជាប់មកជាមួយសំណើ...។ សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថា សំណើ... មិនបានផ្តល់ព័ត៌មាន លម្អិតសម្រាប់ទំនាក់ទំនង ឬក៏បង្ហាញភស្តុតាងដែលរំពឹងថានឹងទទួលបានពីបុគ្គលទាំងនេះឡើយ។ ការយោងតែទៅលើឈ្មោះ និងមុខងារ ដែលបានលើកឡើងក្នុងអំឡុងពេលនៃការស៊ើបអង្កេត គឺជាមូលដ្ឋានមួយដ៏ចង្អៀតសម្រាប់វាយតម្លៃថាតើត្រូវស្តាប់ចម្លើយបុគ្គលនោះ ឬយ៉ាងណា។

[៤] ក្នុងការពិនិត្យឡើងវិញនូវឈ្មោះ និងមុខងាររបស់មនុស្សដែលចុះក្នុងបញ្ជីក្នុងសំណើ... សហចៅក្រមស៊ើអង្កេតយល់ឃើញថា មនុស្សទាំងនោះកាន់តួនាទីតូចតាចនៅក្នុងឋានានុក្រមរបស់ក្រសួងសង្គមកិច្ច។ ដោយមិនមានព័ត៌មានបន្ថែមទៀត សហចៅក្រមស៊ើបអង្កេតយល់ឃើញថា បុគ្គលទាំងនេះដែលមានឈ្មោះនៅក្នុងសំណើ មិនទំនងជាអាចផ្តល់ព័ត៌មានលម្អិតគ្រប់គ្រាន់ទៅលើក្របខណ្ឌនៃការស៊ើបអង្កេត ដែលបង្កើតបានជាមូលដ្ឋាននៃសំណើ...។ ដោយពិចារណាលើ ដំណាក់កាលនៃការស៊ើបអង្កេតថ្មីៗនេះ និងព័ត៌មានដែលមានរួចហើយនៅក្នុងសំណុំរឿង សហចៅក្រមស៊ើបអង្កេតយល់ឃើញថា មិនមានការបង្ហាញឱ្យឃើញ ថាតើបុគ្គលទាំងនេះអាចជួយក្នុងការនាំទៅរកការបង្ហាញការពិតបែបណានោះឡើយ។ ដូច្នេះ សំណើ...គួរត្រូវបានបដិសេធ។

...

[៩] ចុងបញ្ចប់ សហចៅក្រមស៊ើបអង្កេតរំលឹកថា ច្បាប់ អ.វ.ត.ក កិច្ចព្រមព្រៀង និងវិធានផ្ទៃក្នុងមិនតម្រូវឱ្យមានការពិគ្រោះជាមួយភាគីមុនការបំពេញកិច្ចស៊ើបសួរឡើយ។ សហចៅក្រមស៊ើបអង្កេតមិនឃើញមានហេតុផលណាមួយក្នុងការធ្វើការពិគ្រោះនៅដំណាក់លនេះឡើយ។

១៣. ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ ជាការសំខាន់ដែលយើងត្រូវបែងចែកសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតជាប្រាំមួយចំណុចខុសៗគ្នា៖

១) ការគ្មានព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនង [redacted]នេះ។

២) គ្មានការចង្អុលបង្ហាញអំពីភស្តុតាងដែលរំពឹងថានឹងទទួលបាន។

៣) តួនាទីតូចតាចរបស់បុគ្គលទាំងនេះនៅក្នុងឋានានុក្រមនៃក្រសួង។

៤) គ្មានព័ត៌មានបន្ថែម។

៥) ដំណាក់កាលស៊ើបអង្កេតនាពេលបច្ចុប្បន្ន។ និង

៦) ព័ត៌មានដែលមានរួចហើយនៅក្នុងសំណុំរឿង។

**បញ្ហាបឋម ÷ ភាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការពិគ្រោះជាមួយនឹងភាគីស្នើសុំ**

00531875



១៤. យោងតាមមូលដ្ឋានទីមួយនៃបណ្ដឹងឧទ្ធរណ៍ និងជាមូលដ្ឋានទាំងមូលនៃបណ្ដឹងឧទ្ធរណ៍ផងដែរនោះ[១៤] ដើមបណ្ដឹងឧទ្ធរណ៍បានសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេត "គួរតែឆ្លើយតបនឹងសំណើរបស់មេធាវីការពារក្ដី ដែលស្នើឱ្យមានការពិភាក្សាលើព័ត៌មានលម្អិតបន្ថែម [redacted] នេះ"[១៥]។ ដោយហេតុថា ការសន្និដ្ឋាននេះរបស់ដើមបណ្ដឹងឧទ្ធរណ៍ហាក់ដូចជាមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ទាំងមូល អង្គបុរេជំនុំនឹងពិចារណាចំណុចនេះមុនគេ។

១៥. ដើមបណ្ដឹងឧទ្ធរណ៍បានដកស្រង់[១៦]សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះនៅក្នុង *សេចក្ដីសម្រេចអំពីការចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ និងសេចក្ដីអញ្ជើញសហព្រះរាជអាជ្ញាឱ្យបំភ្លឺអំពីជំហររបស់ខ្លួន*[១៧] មកធ្វើជាមូលដ្ឋានគាំទ្រនូវការសន្និដ្ឋានរបស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចទទួលយកសំណើរបស់ដើមបណ្ដឹងឧទ្ធរណ៍ដែលស្នើសុំឱ្យមានការពិគ្រោះយោបល់។ សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះនេះមិនបានបង្កើតកាតព្វកិច្ចបែបនេះឡើយ។

១៦. ស្ថានភាពនៅពេលអង្គបុរេជំនុំជម្រះចេញសេចក្ដីសម្រេច ដែលដើមបណ្ដឹងឧទ្ធរណ៍បានដកស្រង់នោះគឺថា អង្គបុរេជំនុំជម្រះមិនយល់ច្បាស់ថា តើសហព្រះរាជអាជ្ញា (ស.ព) មានបំណងដាក់សំណើសុំលើកទីមួយរបស់ខ្លួន ជាសំណើសុំបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ឬក៏ជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម អនុលោមតាមវិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង។ នៅក្នុងស្ថានភាពនោះហើយដែលអង្គបុរេជំនុំជម្រះបានលើកឡើងថា៖

> [បន្ទាប់]ពីបានពិចារណាលើសារៈសំខាន់នៃបញ្ហានេះ វាទំនងជានឹងមានលក្ខណៈសមហេតុផលសម្រាប់ ស.ច.ស ប្រសិនបើ ស.ច.ស សុំការបំភ្លឺពីសហព្រះរាជអាជ្ញាថា តើសំណើទីមួយរបស់សហព្រះរាជអាជ្ញាចង់មានន័យថាជាសំណើអ្វី។ តាមរយៈដីកាដែលត្រូវជជែកតវ៉ា ឬដីកាបដិសេធ វាមានភាពមិនច្បាស់លាស់ថាតើ ស.ច.ស បានធ្វើដូច្នេះ ឬក៏អត់។...អង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីជាប្រយោជន៍

[១៤] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ៤៣ កថាខណ្ឌទី ៧៣។

[១៥] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ៣៣។

[១៦] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ៣៣ កថាខណ្ឌទី ៧៣។

[១៧] ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០ D250/3/2/1/2។



អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

នៃយុត្តិធម៌ វាទាមទារឱ្យអង្គបុរេជំនុំជម្រះស្នើឱ្យមានការបំភ្លឺពីសហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងបញ្ហានេះ មុនពេលចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ទាំងនេះ[១៨]។

១៧. ចំណុចពីរនៅក្នុងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ មិនមែនជាមូលដ្ឋានគាំទ្រដល់ការ សន្និដ្ឋានរបស់ដើមបណ្ដឹងឧទ្ធរណ៍ ដែលបានលើកឡើងថា អនុលោមតាមច្បាប់ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចត្រូវពិគ្រោះយោបល់ជាមួយនឹងដើមបណ្ដឹងឧទ្ធរណ៍។ ចំណុចទីមួយ អង្គបុរេជំនុំជម្រះមិនបានលើកឡើងថា អនុលោមតាមច្បាប់ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចសុំការបំភ្លឺពី ស.ព ឡើយ, គ្រាន់តែថា ការធ្វើដូច្នេះនឹងមាន "ភាពសមហេតុផល" ចំពោះសហចៅក្រមស៊ើបអង្កេត។ ចំណុចទីពីរ អង្គបុរេជំនុំជម្រះមិនបានលើកឡើងថា ផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យសហចៅក្រមស៊ើបអង្កេតស្នើសុំការបំភ្លឺពី ស.ព ឡើយ ដែលវាខុសនឹងអ្វីដែលបណ្ដឹងឧទ្ធរណ៍ថាបានដកស្រង់ពី សេចក្ដីសម្រេចនោះ[១៩]។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះយល់ឃើញថា ផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យខ្លួនស្នើសុំការបំភ្លឺពី ស.ព មុនពេលខ្លួនធ្វើការសម្រេចលើបណ្ដឹងឧទ្ធរណ៍ទាំងឡាយដែលបានប្ដឹង[២០]។

១៨. សហចៅក្រមស៊ើបអង្កេតពិតជាត្រឹមត្រូវក្នុងការលើកឡើងថា ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ កិច្ចព្រមព្រៀង ឬវិធានផ្ទៃក្នុង មិនមានបទប្បញ្ញត្តិចែងដាក់កាតព្វកិច្ចយ៉ាងជាក់លាក់ឱ្យសហចៅក្រមស៊ើបអង្កេតពិគ្រោះជាមួយនឹងភាគីស្នើសុំ មុនពេលខ្លួនបំពេញ កិច្ចស៊ើបសួរឡើយ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្ដី "ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ផលប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ... ត្រង់ចំណុចនេះ៖ ក) ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានភាពយុត្តិធម៌..."[២១]។ កិច្ចព្រមព្រៀងក៏

---

[១៨] សេចក្ដីសម្រេចអំពីការចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ និងសេចក្ដីអញ្ជើញសហព្រះរាជអាជ្ញាឱ្យបំភ្លឺអំពីជំហររបស់ខ្លួន ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០ D250/3/2/1/2 កថាខណ្ឌទី ១៣។

[១៩] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ៣៣។

[២០] ហេតុដូច្នេះហើយ អង្គបុរេជំនុំជម្រះ "អញ្ជើញសហព្រះរាជអាជ្ញាឱ្យបំភ្លឺបញ្ហានេះ..." (សេចក្ដីសម្រេចអំពីការចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ និងសេចក្ដីអញ្ជើញសហព្រះរាជអាជ្ញាឱ្យបំភ្លឺអំពីជំហររបស់ខ្លួន ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០ D250/3/2/1/2, ទំព័រ ៨។

[២១] វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង។



អង្គបុរេជំនុំជម្រះ E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

តម្រូវឱ្យសហចៅក្រមស៊ើបអង្កេតអនុវត្តយុត្តាធិការរបស់ខ្លួន ឱ្យស្របទៅនឹងមាត្រា ១៤-១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ (“ក.អ.ស.ព.ន”)[២២]។

១៩. អង្គបុរេជំនុំជម្រះមានហេតុផលចំនួនបី ក្នុងការបដិសេធមិនផ្តល់ការយល់ឃើញរបស់ខ្លួននៅក្នុងសាលដីកានេះ ត្រង់ចំណុចថា តើសហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចពិគ្រោះយោបល់ជាមួយភាគីស្នើសុំដែរឬទេ អនុលោមតាមវិធាន ៥៥(១០) និងវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុង ហើយថាតើការពិគ្រោះយោបល់នោះត្រូវធ្វើឡើងត្រឹមកម្រិតណា។ ហេតុផលទីមួយ គឺបណ្តឹងឧទ្ធរណ៍នេះមិនបានសន្និដ្ឋានថាតើ ភាពយុត្តិធម៌ ឬ ក.អ.ស.ព.ន (ឬច្បាប់ជាតិ និងអន្តរជាតិ ដទៃទៀត) បានដាក់កាតព្វកិច្ច ដល់សហចៅក្រមស៊ើបអង្កេតឱ្យពិគ្រោះយោបល់ នៅក្នុងករណីនៃបណ្តឹងឧទ្ធរណ៍បែបនេះដែរឬទេ ហើយថាតើវាបានដាក់កាតព្វកិច្ចនេះត្រឹមកម្រិតណា។ អង្គបុរេជំនុំជម្រះមិនមានកាតព្វកិច្ចលើកឡើងនូវចំណុចសន្និដ្ឋាននេះជំនួសឱ្យភាគី ដែលមិនបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ឡើយ។ ហេតុផលទីពីរ អង្គបុរេជំនុំជម្រះនៅមានមន្ទិលសង្ស័យថា ដើមបណ្តឹងឧទ្ធរណ៍ មិនបានមានការប្រុងប្រយ័ត្ន ដោយខកខានមិនបានបញ្ចូល “ព័ត៌មានទំនាក់ទំនងបន្ថែម...ចំពោះសាក្សីទាំង[ប្រាំបួនរូប]ដែលសំខាន់ៗនេះ” នៅក្នុងសំណើ។ យោងតាមបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងឧទ្ធរណ៍បានពន្យល់ថា “ដោយគិតពីផលប្រយោជន៍របស់[redacted]នេះ មេធាវីការពារក្តីបានសម្រេចចិត្តមិនផ្តល់ ក.ស.ច.ស នូវអស័យដ្ឋានទំនាក់ ទំនងលម្អិតរបស់[redacted]នេះ ដែល ក.ស.ច.ស ស្នើសុំដើម្បីធ្វើកិច្ចស៊ើបសួរ ព្រោះការរក្សាភាពសម្ងាត់ដល់សាក្សីសក្តានុពល គឺជាធាតុផ្សំដ៏សំខាន់មួយក្នុងការការពារសាក្សី។ នេះគឺជាហេតុផលចំបងថាហេតុអ្វីបានជាមេធាវីការពារក្តីបានស្នើ ក.ស.ច.ស ពិគ្រោះយោបល់ជាមួយខ្លួនជាមុនសិន...”[២៣]។ ដើមបណ្តឹងឧទ្ធរណ៍មិនបានពន្យល់ថាហេតុអ្វីបានជាខ្លួនមិនអាចដាក់បញ្ចូលនូវសេចក្តីពន្យល់លើចំណុចនេះនៅក្នុងសំណើ ឬហេតុអ្វីខ្លួនមិនបានដាក់បញ្ចូលនូវព័ត៌មានលម្អិត ដែលខ្លួនបានថា សម្ងាត់នោះ ក្នុងទម្រង់ជាព័ត៌មាន សម្ងាត់បំផុតដោយភ្ជាប់នៅក្នុងឧបសម្ព័ន្ធមកជាមួយនឹងសំណើ អនុលោមតាមមាត្រា៣ នៃសេចក្តីណែនាំអនុវត្តអំពី “ការដាក់ឯកសារនៅ អ.វ.ត.ក”។

[២២] មាត្រា ១២ - ១៣ កិច្ចព្រមព្រៀង អ.វ.ត.ក។ *សូមមើលផងដែរ* មាត្រា ៤៧ ស្ទួន ថ្មី ច្បាប់ អ.វ.ត.ក។

[២៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៧២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

២០. ហេតុផលទីបី និងជាហេតុផលចុងក្រោយ ដែលថា បានជាអង្គបុរេជំនុំជម្រះបដិសេធមិនឆ្លើយទៅនឹងការចោទសួរត្រង់ចំណុចថា តើសហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចពិគ្រោះយោបល់ជាមួយភាគីស្នើសុំដែរឬទេ ហើយថា តើការពិគ្រោះយោបល់នោះត្រូវធ្វើឡើងត្រឹមកម្រិតណា គឺឈរលើហេតុផលថា ដើមបណ្តឹងឧទ្ធរណ៍មិនបានបង្ហាញហេតុផល *ជាបឋម(prima facie)* ឱ្យអង្គបុរេជំនុំជម្រះជឿថា ការពិគ្រោះយោបល់នោះ ប្រសិនបើធ្វើឡើង នឹងអាចឱ្យសហចៅក្រមស៊ើបអង្កេតប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការទទួលយកសំណើនោះបាន។ “ព័ត៌មានពិស្តារបន្ថែម...អំពី [redacted] ដែល សំខាន់នេះ” ដែលដើមបណ្តឹងឧទ្ធរណ៍អះអាងថា ខ្លួននឹងផ្តល់ជូនដល់សហចៅក្រមស៊ើបអង្កេតនៅពេលពិគ្រោះយោបល់ រួមមាន “ប្រវត្តិ និងការងារមុនឆ្នាំ១៩៧៥ ក្នុងអំឡុងឆ្នាំ១៩៧៥-ឆ្នាំ១៩៧៩ និងក្រោយឆ្នាំ១៩៧៥ ជាដើម [sic]”[២៤] និង “ព័ត៌មានពិស្តារសម្ងាត់” ដទៃទៀត ដែលទំនងជារួមទាំង “អស័យដ្ឋានទំនាក់ទំនង”[២៥]។ នៅពេលអានអត្ថន័យជុំវិញដីកាសម្រេចនេះ យើងយល់ឃើញថា អង្គបុរេជំនុំជម្រះមិនឃើញមាន ហេតុផល *ជាបឋម* ដែលអាចឱ្យជឿថា សហចៅក្រមស៊ើបអង្កេតនឹងទទួលយកសំណើ នោះ ប្រសិនបើសហចៅក្រមស៊ើបអង្កេតបានពិចារណាលើព័ត៌មានទាំងនោះឡើយ។

## មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ ÷ ដីកាដែលមានសំអាងហេតុមិនគ្រប់គ្រាន់

២១. ដើមបណ្តឹងឧទ្ធរណ៍សន្និដ្ឋានថា ដីកាសម្រេចនេះ “មិនមានសំអាងហេតុគ្រប់គ្រាន់ ដែលវារំលោភបំពានលើវិធាន ៥៥(១០)នៃវិធានផ្ទៃក្នុង ដែលទង្វើនេះបង្កើតឱ្យមានការរំលោភលើគោលការណ៍ទូទៅនៃច្បាប់ដែលថា សេចក្តីសម្រេចរបស់តុលាការមួយ ត្រូវតែមានបញ្ជាក់ពីសំអាងហេតុ។ ការខកខានមិនបានបញ្ជាក់សំអាងហេតុនេះ នឹងបណ្តាលឱ្យច្រានចោលនូវដីកាសម្រេច”[២៦]។ ជាពិសេស ដើមបណ្តឹងឧទ្ធរណ៍បានសន្និដ្ឋានថា “ក.ស.ច.ស” (យើងចាត់ទុកថា សំដៅលើសហចៅក្រមស៊ើបអង្កេត)៖

---

[២៤] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៣២។

[២៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៧១ - ៧៣។

[២៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៣៨។

[៣២] [ខកខាន]មិនបានផ្តល់សំអាងហេតុចំពោះការសន្និដ្ឋានរបស់ខ្លួនដែលលើកឡើងថា [redacted] នេះ ... ប្រហែលមិនអាចផ្តល់ឱ្យ ក.ស.ច.ស នូវព័ត៌មានលម្អិតគ្រប់គ្រាន់សម្រាប់កិច្ចស៊ើបសួរឡើយ។... [ក.ស.ច.ស] បានបដិសេធមិនព្រមទទួលយកសំណើរបស់មេធាវីការពារក្តី ដែលស្នើសុំឱ្យមានការពិភាក្សាលើព័ត៌មានលម្អិតបន្ថែមរបស់សាក្សីសំខាន់ៗទាំងនេះ ហើយផ្ទុយទៅវិញ ក.ស.ច.ស បានចេញដីកាថា មេធាវីការពារក្តី មិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ ទាក់ទងនឹងសាក្សីសំខាន់ៗទាំងនេះ ព្រមទាំងធ្វើការច្រានចោលសំណើ។ បន្ថែមលើនេះទៀត ក.ស.ច.ស ខកខានមិនបានផ្តល់នូវសំអាងហេតុផ្សេងៗ ដែលបញ្ជាក់ពីមូលហេតុអ្វីដែលខ្លួនបានចេញសេចក្តីសម្រេចនេះឡើយ។

...

[៣៥] ក.ស.ច.ស មិនបានផ្តល់ឱ្យមេធាវីការពារក្តីនូវឯកសារយោង ឬ ប្រភពព័ត៌មាននូវអ្វីដែលក.ស.ច.ស លើកឡើងថា៖ "ព័ត៌មានមាននៅក្នុងសំណុំរឿងក្តីរួចទៅហើយ" នេះទេ។ ផ្ទុយទៅវិញ ក.ស.ច.ស បានលើកឡើងដោយសំដៅដល់សំណុំរឿងក្តីទាំងមូលតែម្តង។

...

[៣៧] ដីកាសម្រេចនេះខ្វះសំអាងហេតុ ដោយគ្រាន់តែធ្វើការអះអាងជាទូទៅតែប៉ុណ្ណោះ។ លើសពីនេះទៀត ដីកាសម្រេចនេះ មិនបានបង្ហាញឱ្យឃើញចំពោះព័ត៌មានលម្អិតគ្រប់គ្រាន់ដែលលើកឡើងថាភស្តុតាងដោះបន្ទុក ស្នើឡើងដោយមេធាវីការពារក្តីមានរួចទៅហើយនៅក្នុងសំណុំរឿងក្តីបច្ចុប្បន្ន។ ដោយយោងមូលហេតុនេះ ត្រូវតែច្រានចោលដីកាសម្រេចនេះ។

២២. វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង តម្រូវឱ្យសហចៅក្រមស៊ើបអង្កេត "បង្ហាញសំអាងហេតុចំពោះការសម្រេចបដិសេធការបំពេញកិច្ចស៊ើបសួរ។ វិធាន៥៥(១០) នៃវិធានផ្ទៃក្នុងជាភាសាបារាំងត្រូវបានបកប្រែជាភាសាអង់គ្លេសថា ដីកាសម្រេច[បដិសេធ] ត្រូវមានសំអាងហេតុ"។ វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងជាភាសាខ្មែរ មានបទប្បញ្ញត្តិដូចគ្នានឹងភាសាអង់គ្លេស ("សំអាងហេតុ")។ វិធាន៥៨(៦) នៃវិធានផ្ទៃក្នុងជាភាសាអង់គ្លេស ចែងថា ដីកាសម្រេចបដិសេធសំណើរបស់ជនត្រូវចោទ សុំបំពេញកិច្ចស៊ើបសួរ "ត្រូវមានការបញ្ជាក់មូលហេតុពិតប្រាកដ"។ វិធាន៥៨(៦)[២៧] នៃវិធានផ្ទៃក្នុង ជាភាសាបារាំង មិនមានពាក្យបញ្ជាក់"ពិតប្រាកដ"ឡើយ ប៉ុន្តែវិធាននេះមានពាក្យពេចន៍ដូចគ្នានឹងវិធាន៥៥(១០) នៃវិធានផ្ទៃក្នុងជាភាសាបារាំង។ វិធាន ៥៨(៦)

---

[២៧] "La demande est formulée par écrit et motivée"។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

នៃវិធានផ្ទៃក្នុងជាភាសាបារាំង ហាក់ដូចជាស្របគ្នាជាមួយនឹងច្បាប់កម្ពុជា និងច្បាប់បារាំង[២៨] ជាងវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុងជាភាសាអង់គ្លេស។ ដូច្នេះ អង្គបុរេជំនុំជម្រះត្រូវធ្វើការពិចារណា ដោយផ្អែកលើបទប្បញ្ញត្តិទាំងនេះដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងជាភាសាបារាំង និងភាសាខ្មែរ។

២៣. បញ្ហាចោទនៅចំពោះមុខអង្គបុរេជំនុំជម្រះ គឺថាតើសហចៅក្រមស៊ើបអង្កេតត្រូវផ្តល់សំអាងហេតុក្នុងកម្រិតលម្អិតប៉ុណ្ណា អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។ បទដ្ឋានណែនាំមួយចំនួនចំពោះបញ្ហាចោទនេះ ឃើញមានចែងនៅក្នុងវិធានផ្ទៃក្នុង។ ចំណុចទីមួយ ដើម្បីឱ្យសិទ្ធិប្តឹងឧទ្ធរណ៍របស់ជនត្រូវចោទអនុលោមតាមវិធាន ៧៤(៣) (ខ) អនុវត្តបានពេញលេញ ជនត្រូវចោទត្រូវដឹងមូលហេតុដែលសហចៅក្រមស៊ើបអង្កេតបដិសេធសំណើរបស់ខ្លួន។ករណីនេះតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតផ្តល់សំអាង ហេតុលើសេចក្តីសម្រេចបដិសេធរបស់ខ្លួន ឱ្យបានលម្អិតគ្រប់គ្រាន់ ដើម្បីបង្ហាញអំពីមូលដ្ឋាននៃសេចក្តីសម្រេចបដិសេធរបស់ខ្លួន។ ការធ្វើដូច្នេះ ដាក់ជនត្រូវចោទក្នុងស្ថានភាពមួយអាចឱ្យគេសម្រេចថា តើត្រូវប្តឹងឧទ្ធរណ៍ដែរឬទេ ហើយត្រូវប្តឹងប្រឆាំងនឹងសំអាងហេតុចំណុចមួយណា និងអាចឱ្យគេរៀបចំសេចក្តីសន្និដ្ឋានឱ្យបានសមស្របដើម្បីជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍។ ចំណុចទីពីរ វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង ទាមទារឱ្យអង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេច "ដោយមានសំអាងហេតុ" លើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៥៥ (១០)នៃវិធានផ្ទៃក្នុង។ វិធានផ្ទៃក្នុងមិនអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះតម្កល់ទុកការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតដែលបានសម្រេចបដិសេធសំណើឡើយ ប្រសិនបើខ្លួនមិនដឹងហេតុផលដែលសហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធលើសំណើនោះ។ វិធានផ្ទៃក្នុងក៏តម្រូវឱ្យសហចៅក្រមស៊ើបអង្កេតផ្តល់សំអាងហេតុលើសេចក្តីសម្រេចបដិសេធរបស់ខ្លួន ឱ្យបានលម្អិតគ្រប់គ្រាន់ ដើម្បីអាចឱ្យអង្គបុរេជំនុំជម្រះពិនិត្យលើបណ្តឹងឡើងវិញឱ្យមានប្រសិទ្ធភាព។

---

[២៨] មាត្រា ១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា ដីកាបដិសេធ "ត្រូវមានសំអាងហេតុ" និងមាត្រា ៨២-១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសបារាំងចែងថា "សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ"។

២៤. បទដ្ឋានណែនាំមួយចំនួន ក៏ឃើញមាននៅក្នុងសាលក្រមដែលបានសម្រេចជាឯកច្ឆន្ទដោយអង្គជំនុំជម្រះនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប ហើយសាលក្រមនេះបានលើកឡើងយោងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះផងដែរ[២៩]។ នៅក្នុងរឿងក្តី *Taxquet* ទល់នឹង *បែលហ្ស៊ិក*[៣០] តុលាការ Liège Assize ដោយមានសមាសភាពក្រុមប្រឹក្សាវិនិច្ឆ័យ(Jury) បានសម្រេចឱ្យដើមបណ្តឹងជាប់ទោសពីបទមនុស្សឃាតលើរដ្ឋមន្ត្រីមួយរូបរបស់រដ្ឋាភិបាល និងបទប៉ុនប៉ងមនុស្សឃាតដៃគូររបស់រដ្ឋមន្ត្រីរូបនោះ។ ច្បាប់ប្រទេសបែលហ្ស៊ិកមិនតម្រូវឱ្យក្រុមប្រឹក្សាវិនិច្ឆ័យផ្តល់សំអាងហេតុលើសាលក្រមឡើយ ហើយក្រុមប្រឹក្សាវិនិច្ឆ័យ ព្រមទាំងតុលាការ Assize នេះ មិនបានផ្តល់សំអាងហេតុនានាក្នុងសាលក្រមនេះដែរ។ តុលាការកំពូលបានបដិសេធបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងចាត់ទុកជាឥតបានការ។

២៥. នៅចំពោះមុខតុលាការសិទ្ធិមនុស្សអឺរ៉ុប ដើមបណ្តឹងបានចោទប្រកាន់ក្នុងចំណុចមួយចំនួន ក្នុងនោះចំណុចមួយថាសិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មិនត្រូវបានគេគោរពឡើយ ដោយហេតុថា ការសម្រេចឱ្យជាប់ទោសដោយតុលាការ Assize មិនបានផ្តល់នូវសំអាងហេតុ។ ដើមបណ្តឹងបានយកមាត្រា ៦(១)នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប (អ.ស.ម.អ) មកធ្វើជាមូលដ្ឋាន ដែលនៅក្នុងបទប្បញ្ញត្តិដែលពាក់ព័ន្ធចែង ដូចតទៅ៖

> នៅពេលចេញសេចក្តីសម្រេចលើបទព្រហ្មទណ្ឌចំពោះខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះ... ដោយយុត្តិធម៌... ដោយសាលាក្តី...

២៦. ដោយមានហេតុផលដូចខាងក្រោមនេះ អង្គជំនុំជម្រះនៃតុលាការសិទ្ធិមនុស្សអឺរ៉ុបបានសន្និដ្ឋាន[៣១] ថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានរំលោភបំពាន ដែលសិទ្ធិនេះត្រូវបានធានាដោយមាត្រា ៦(១) នៃ អ.ស.ម.អ៖

---

[២៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៥៩។

[៣០] បណ្តឹងលេខ 926/05 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ (*"Taxquet"*)។ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩ ក្រុមប្រឹក្សាជំនុំជម្រះប្រាំរូបនៃអង្គជំនុំជម្រះពេញអង្គ (Grand Chamber) បានទទួលយករឿងក្តីដែលបានបញ្ជូនមកខ្លួន អនុលោមតាមមាត្រា ៤៣ នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប។ សវនាការនៅចំពោះមុខអង្គជំនុំជម្រះពេញអង្គ (Grand Chamber) បានបើកការជំនុំជម្រះនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩។ សាលក្រមនឹងចេញនៅកាលបរិច្ឆេទលើកក្រោយ។

[៣១] *Taxquet* កថាខណ្ឌទី ៥០។



* E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

[៤០] តុលាការ [សិទ្ធិមនុស្ស] [អឺរ៉ុប] បានបញ្ជាក់ឡើងវិញថា យោងតាមយុត្តិសាស្ត្ររបស់ខ្លួន សាលក្រម ឬ សាលដីការបស់តុលាការ ឬ សាលាក្តីទាំងឡាយ ត្រូវផ្តល់សំអាងហេតុឱ្យបានសមរម្យ ដែលសាលក្រម ឬ សាលដីកានោះយកមកធ្វើជាមូលដ្ឋាន។ កាតព្វកិច្ចក្នុងការផ្តល់សំអាងហេតុ អាចកម្រិតខុសទៅតាមលក្ខណៈនៃសេចក្តីសម្រេច ហើយត្រូវសម្រេចដោយផ្អែកលើកាលៈទេសៈនៃរឿងក្តី...។ ទោះបីជាមាត្រា ៦(១) តម្រូវឱ្យតុលាការផ្តល់សំអាងហេតុចំពោះសេចក្តីសម្រេចរបស់ខ្លួនក៏ដោយ យើងមិនអាចនិយាយថា វាជាលក្ខខណ្ឌដែលទាមទារឱ្យផ្តល់សំអាងហេតុលម្អិតលើគ្រប់ទឡ្ហីករណ៍ទាំងអស់នោះទេ...។

...

[៤៣] ចាប់តាំងពីរឿងក្តី *Zarouali*[៣២] មក យើងឃើញមានការប្រែប្រួលជាក់ស្តែងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ [អឺរ៉ុប] និងច្បាប់របស់រដ្ឋហត្ថលេខី។ យោងតាមយុត្តិសាស្ត្ររបស់ខ្លួន តុលាការបានសម្រេចជាញឹកញយថា សំអាងហេតុនៅក្នុងសេចក្តីសម្រេចរបស់តុលាការ ត្រូវតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងផលប្រយោជន៍នៃការធានាដល់ការជំនុំជម្រះដោយយុត្តិធម៌ ដែលធ្វើដូច្នេះ វានឹងការពារសិទ្ធិរបស់ចុងចោទ។ សំអាងហេតុនេះមានប្រយោជន៍ដល់តម្លៃនៃយុត្តិធម៌ ហើយផ្តល់ជាយន្តការក្នុងការការពារការចេញសេចក្តីសម្រេចតាមទំនើងចិត្ត។

...

[៤៨] នៅក្នុងរឿងក្តីនេះ អង្គហេតុ និងអង្គច្បាប់នៅចំពោះក្រុមប្រឹក្សាវិនិច្ឆ័យត្រូវសម្រេចក្នុងរបៀបមួយអាចឱ្យដើមបណ្តឹងម្នាក់ៗធ្វើការតវ៉ាយ៉ាងត្រឹមត្រូវតាមផ្លូវច្បាប់ថា ខ្លួនមិនបានដឹងហេតុផល ដែលត្រូវបានសម្រេចកាត់ទោសលើរូបខ្លួនឡើយ នៅពេលខ្លួនបានបដិសេធអំពីការជាប់ពាក់ព័ន្ធរបស់ខ្លួននៅក្នុងបទល្មើសដែលបានចោទប្រកាន់។ តុលាការពិចារណាឃើញថា សេចក្តីសម្រេចដែលមានចន្លោះប្រហោងបែបនេះលើអង្គហេតុ និងអង្គច្បាប់ទូទៅ និងស្រពិចស្រពិល អាចទុកឱ្យដើមបណ្តឹង មានអារម្មណ៍ថា វាជាការរកយុត្តិធម៌តាមទំនើងចិត្ត ដែលគ្មានតម្លាភាព...។

[៤៩] នៅក្នុងកាលៈទេសៈទាំងនេះ វាធ្វើឱ្យតុលាការកំពូលមិនអាចពិនិត្យលើបណ្តឹងឧទ្ធរណ៍ដោយប្រសិទ្ធភាព ហើយជាឧទាហរណ៍ មិនអាចកំណត់ចំណុចខ្វះខាត ឬ ចំណុចមិនស៊ីសង្វាក់ ទាំងឡាយនៅក្នុងសំអាងហេតុបានឡើយ។

២៧. អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("តុលាការ ICTY") បានបកស្រាយស្រដៀងគ្នានេះដែរ ពីលក្ខខណ្ឌតម្រូវដែលចែងនៅក្នុងមាត្រា ២៣(២) នៃលក្ខន្តិកៈរបស់តុលាការ ICTY និងវិធាន ៩៨ *ស្ទួនពីរ* (គ) នៃវិធានស្តីពីនីតិវិធី និងការដាក់ភស្តុតាងនៅតុលាការ ICTY ដែលតម្រូវថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងណាមួយ

---

[៣២] *Taxquet* ទល់នឹង *បែលហ្សិក* បណ្តឹងលេខ 20664/92 សេចក្តីសម្រេចរបស់គណៈកម្មាការ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៤។



E.C.C.C * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00531883



"ត្រូវភ្ជាប់មកជាមួយ [ឬភ្ជាប់មកតាមក្រោយឲ្យបានលឿន បំផុតអាចធ្វើទៅបាន] នូវយោបល់ដែលមានសំអាងហេតុជាលាយលក្ខណ៍អក្សរ"។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានកត់សម្គាល់ឃើញថា៖

[៣៨៤] នៅក្នុងរឿងក្ដីភាគច្រើន អង្គជំនុំជម្រះសាលាដំបូងមិនបានបង្ហាញអង្គហេតុជាក់លាក់ច្បាស់លាស់ទាក់ទងទៅនឹងធាតុផ្សំនីមួយៗនៃបទឧក្រិដ្ឋទេ ប៉ុន្តែ អង្គជំនុំជម្រះបានសន្និដ្ឋានយ៉ាងច្បាស់ថាបទឧក្រិដ្ឋនោះបានកើតឡើង។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដោយរកឃើញថា បទឧក្រិដ្ឋបានកើតឡើង ដោយប្រយោល អង្គជំនុំជម្រះសាលាដំបូងបានរកឃើញនូវអង្គហេតុពាក់ព័ន្ធទាំងអស់ ដែលជាលក្ខខណ្ឌតម្រូវដើម្បីគ្របដណ្ដប់ធាតុផ្សំនៃបទឧក្រិដ្ឋទាំង នោះ។

[៣៨៥] ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វិធីសាស្ត្របែបនេះមិនបានបំពេញនូវបទដ្ឋានតម្រូវនោះឡើយ។ សាលក្រមចេញពីអង្គជំនុំជម្រះសាលាដំបូង ត្រូវធ្វើឲ្យអង្គជំនុំជម្រះតុលាការកំពូលអាចអនុវត្តកិច្ចការរបស់ខ្លួនបានដោយអនុលោមតាមមាត្រា២៥ នៃលក្ខន្តិកៈ ដោយផ្អែកទៅលើសេចក្ដីសម្រេចគ្រប់គ្រាន់មួយ ដែលបង្ហាញថា តើសម្ភារៈអ្វីខ្លះត្រូវបានទទួលយកធ្វើជាភស្តុតាងបញ្ជាក់ពីធាតុផ្សំនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នោះ។ ប្រសិនបើមានការពិភាក្សាធ្វើឡើង ត្រូវធ្វើការវាយតម្លៃទៅលើក្នុងចំណោមចំណុចផ្សេងៗគឺភាពគួរឲ្យជឿជាក់បាន និងអាកប្បកិរិយារបស់សាក្សីណាមួយ។ ការផ្អែកជាផ្នែកទៅលើឃ្លាទូទៅមួយ[៣៣] មិនអាចជំនួសកាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្ដល់នូវ "យោបល់ដែល មានសំអាងហេតុជាលាយលក្ខណ៍អក្សរ" ដូចដែលរំពឹងទុកនៅក្នុងមាត្រា ២៣(២) ប្រយោគទី២ នៃលក្ខន្តិកៈ ដែលបានរៀបរាប់ខាងលើនោះទេ។

---

[៣៣] ជើងទំព័រ ៥៨៣ នៅក្នុងសាលក្រមរបស់តុលាការឧទ្ធរណ៍ ដល់កថាខណ្ឌ ២០ នៃសាលក្រមរបស់តុលាការសាលាដំបូងថែងថា៖ "តាមការពិភាក្សារបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង នឹងចាត់ទុកភស្តុតាងបែបនេះថាមានសារៈសំខាន់សម្រាប់គោលបំណងនៃសាលក្រម។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងផ្តោតទៅផ្នែកទាំងឡាយណាយដែលមានសារៈសំខាន់ជាងគេ ហើយនឹងសង្ខេបខ្លីៗ (ឬមិនរៀបរាប់តែម្តង) ចំពោះភស្តុតាងបន្ទាប់បន្សំ។ ព័ត៌មានលម្អិតជាច្រើនត្រូវបានបង្ហាញនៅក្នុងសំណុំរឿងនេះ (ច្រើនពេក បើតាមទស្សនៈរបស់តុលាការសាលាដំបូង)។ ភាពពិតដែលថាបញ្ហានេះមិនត្រូវបានរៀបរាប់នៅក្នុងសាលក្រមនោះ មិនមានន័យថាបញ្ហានោះមិនត្រូវបានគេយកចិត្តទុកដាក់នោះទេ។ រាល់ភស្តុតាងទាំងអស់ត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង ហើយតម្លៃផ្តល់ឲ្យភស្តុតាងទាំងនោះមានសមាមាត្រដោយសមហេតុផល។ ប៉ុន្តែមានតែបញ្ហាចាំបាច់សម្រាប់គោលបំណងសាលក្រមតែប៉ុណ្ណោះ ដែលត្រូវបានបញ្ចូល[illegible]"

00531884



២៨. បើទោះជាយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប[៣៤] និងរបស់តុលាការ ICTY មានភាពពាក់ព័ន្ធទៅនឹងសាលក្រមលើពិរុទ្ធភាពក៏ដោយ ក៏ការយោងទៅលើយុត្តិសាស្ត្រទាំង នេះមានភាពពាក់ព័ន្ធទៅនឹងបរិបទមុនអង្គសេចក្តីនៅ អ.វ.ត.ក នេះដែរ។ ទាំងភាគីដែល សំណើរបស់ខ្លួនត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ត្រូវដឹងអំពីមូលហេតុនៃការបដិសេធនោះឱ្យបានលម្អិតគ្រប់គ្រាន់ ដើម្បីឱ្យដើមបណ្តឹងឧទ្ធរណ៍សម្រេចបានថា តើត្រូវប្តឹងឧទ្ធរណ៍ឬទេ ហើយបើត្រូវប្តឹង តើបណ្តឹងឧទ្ធរណ៍នោះ គួរតែផ្អែកទៅលើមូលដ្ឋានអ្វី និងដើម្បីឱ្យអង្គបុរេជំនុំជម្រះមានលទ្ធភាពសម្រេចថាតើសហចៅក្រមស៊ើបអង្កេតមានកំហុសដែរឬទេ។

២៩. អង្គបុរេជំនុំជម្រះពិចារណាឃើញថា សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ដែលថា "ព័ត៌មាន" មាននៅក្នុងសំណុំរឿងរួចហើយនោះ "ធ្វើឡើងតាមបែបមួយ" ដែលដើមបណ្តឹងឧទ្ធរណ៍ "អាចតវ៉ាបានយ៉ាងស្របច្បាប់" ដោយអះអាងថា ខ្លួនមិនដឹងពីសំអាងហេតុនៃសេចក្តីសន្និដ្ឋាននេះទេ។ អង្គបុរេជំនុំជម្រះក៏យល់ឃើញដែរថា សេចក្តីសន្និដ្ឋាន ដែលមានសំអាងហេតុមិនគ្រប់គ្រាន់បែបនេះ មិនអាចឱ្យអង្គបុរេជំនុំជម្រះអនុវត្តកិច្ចការរបស់ខ្លួន "ក្នុងការពិនិត្យឱ្យមានប្រសិទ្ធភាព" ទៅលើសេចក្តីសន្និដ្ឋាននោះ ហើយរាំងអង្គបុរេជំនុំជម្រះ មិនឱ្យអាច"កំណត់" ពីការអនុវត្តត្រឹមត្រូវទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត។

៣០. ហេតុដូចនេះ អង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតមិនបានបកស្រាយច្បាប់ជាធរមានឱ្យបានត្រឹមត្រូវទេ ដោយសហចៅក្រមមិនព្យាយាមកំណត់ឱ្យជាក់លាក់ពី"ព័ត៌មានដែលមាននៅក្នុងសំណុំរឿងរួចហើយនោះ"។ សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិ ក្នុងការសម្រេចពីកម្រិតនៃភាពលម្អិតជាក់លាក់ដែលតម្រូវដោយក្របខណ្ឌការងារនៃ អ.វ.ត.ក បើទោះជាអង្គបុរេជំនុំជម្រះអាចពិនិត្យឆន្ទានុសិទ្ធិនេះ បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍ ដែលត្រូវបានទទួលយក។ សហចៅក្រមស៊ើបអង្កេត ត្រូវអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយគោរពតាមគោលបំណងនៃលក្ខខណ្ឌ

[៣៤] *សូមមើលផងដែរ៖* គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ *មតិយោបល់ទូទៅលេខ ៣២៖ អត្ថបទ ១៤៖ សិទ្ធិស្តីពីសមភាពនៅចំពោះមុខតុលាការ និងសិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌មួយ* កថាខណ្ឌ ៤៩ ឯកសាររបស់អង្គការសហប្រជាជាតិ ឯកសារលេខ CCPR/C/GC/32 (ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២00៧) និង *រឿងក្តី Smith តទល់នឹង Jamaica* ទស្សនទានរបស់គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ កថាខណ្ឌ ១០.៥ ឯកសាររបស់អង្គការសហប្រជាជាតិ ឯកសារលេខ CCPR/C/47/D/282/1988 (ចុះថ្ងៃទី៣១ ខែមីនា [illegible]) *សាលដីកាលើបណ្តឹងឧទ្ធរណ៍សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកា[illegible]ស៊ើបសួរ* ១៧ *របស់សហមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០*

តម្រូវដែលមានចែងនៅក្នុងវិធាន៥៥(១០) ក្នុងការបដិសេធដោយមានសំអាង ហេតុ ចំពោះសំណើណាមួយ ដូចបានរៀបរាប់ខាងលើនេះ។ អង្គបុរេជំនុំជម្រះមិនមានន័យថា សហចៅក្រមស៊ើបអង្កេតគួរបានផ្តល់ ព័ត៌មានលម្អិតអំពី"ព័ត៌មានទាំងអស់ដែលមាននៅក្នុងសំណុំរឿង"ឡើយ, ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតគួរបានផ្តល់ឲ្យយ៉ាងហោចណាស់ ព័ត៌មានគម្រូ ដែលអាចជា លេខឯកសារពាក់ព័ន្ធ តាមការសមស្រប។ ប្រសិនបើលេខឯកសារមិនអាចរកបាន សហចៅក្រមស៊ើបអង្កេតត្រូវផ្តល់ព័ត៌មានលម្អិតគ្រប់គ្រាន់ស្តីពីប្រភព ទីកន្លែង និងខ្លឹមសារនៃព័ត៌មានគំរូ ដែលយកចេញពីព័ត៌មានដែលមានរួចនៅក្នុង សំណុំរឿង។

៣១. កំហុសអង្គច្បាប់របស់សហចៅក្រមស៊ើបអង្កេត នឹងតម្រូវឲ្យអង្គបុរេជំនុំជម្រះច្រានចោលដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនមានសំអាងហេតុដែលមានសុពលភាពផ្សេងទៀត សម្រាប់ដីកាសម្រេចរបស់ខ្លួននោះទេ។ ដូចដែលនឹងពន្យល់នៅខាងក្រោមនេះ អង្គបុរេជំនុំជម្រះសម្រេចថា មានសំអាងហេតុដែលមានសុពលភាព ផ្សេងៗទៀតដែលគាំទ្រដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនេះ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះនឹងមិនច្រានចោលដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដោយ មូលហេតុកំហុសអង្គច្បាប់នេះទេ។

**មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ ÷ ការអនុវត្តបទដ្ឋានច្បាប់មិនបានត្រឹមត្រូវ**

៣២. ដើមបណ្តឹងឧទ្ធរណ៍តវ៉ាទៅលើសំអាងហេតុបួនក្នុងចំណោមសំអាងហេតុចំនួនប្រាំមួយ ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ១៣ខាងលើ ដែលសហចៅក្រមស៊ើបអង្កេតយកធ្វើជាមូលដ្ឋានក្នុងការបដិសេធសំណើសុំ។ អង្គបុរេជំនុំជម្រះនឹងពិចារណាចំណុចតវ៉ាទាំងនេះនីមួយៗដោយឡែកៗពីគ្នា។

**ការគ្មានព័ត៌មានលម្អិតរបស់[redacted]**

៣៣. ដើមបណ្តឹងឧទ្ធរណ៍លើកឡើងថា"ការដាក់បញ្ចូលព័ត៌មានសម្រាប់ទំនាក់ទំនងរបស់សាក្សីសំខាន់ៗនោះ នៅក្នុងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរផ្ទាល់ មិនមែនជាលក្ខខណ្ឌតម្រូវដើម្បីឲ្យសំណើបែបនោះអាចទទួលយកបានទេ... គ្មានចំណុចណាមួយដែលបានណែនាំ [ដោយសហចៅក្រម



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះ]ថា ភាគីត្រូវតែផ្តល់នូវព័ត៌មានលម្អិតសម្រាប់ទាក់ទងសាក្សីសំខាន់ៗ ជាផ្នែកមួយនៃសំណើនោះទេ”[៣៥]។

៣៤. ដើមបណ្តឹងឧទ្ធរណ៍លើកឡើងត្រឹមត្រូវដែលថា សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរណាមួយ ដែលអនុលោមតាមវិធាន ៥៥(១០) ដើម្បីស្តាប់ចម្លើយបុគ្គលមួយរូប មិនត្រូវបានតម្រូវឱ្យបញ្ចូលនូវព័ត៌មានទំនាក់ទំនងលម្អិតថ្មីៗរបស់បុគ្គលនោះឡើយ[៣៦]។ ទោះបីជាយ៉ាងនេះក្តី អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងដីកាសម្រេច សហចៅក្រមស៊ើបអង្កេតមិនបានប្រកាន់ជំហរផ្ទុយពីនេះណាមួយនោះទេ មិនថាផ្ទាល់ ឬដោយប្រយោលក្តី។ ការអានដីកាសម្រេចនេះ ដោយពិចារណាទៅលើបរិបទ ក៏បង្ហាញផងដែរថា សហចៅក្រមស៊ើបអង្កេតមិនបានចាត់ទុកការគ្មានព័ត៌មានទំនាក់ទំនងលម្អិតទាំងនេះថា ជាមូលដ្ឋានសំខាន់ក្នុងការសម្រេចបដិសេធសំណើសុំទេ។ ការពិតទៅ សហចៅក្រមស៊ើបអង្កេតអាចមិនបាន សូម្បីតែផ្អែកមួយផ្នែកទៅលើការគ្មានព័ត៌មានទំនាក់ទំនងលម្អិតនោះ ដើម្បីសម្រេចលើបដិសេធសំណើសុំឡើយ។ សេចក្តីយោងរបស់សហចៅក្រមស៊ើបអង្កេតទៅលើការគ្មានព័ត៌មានទំនាក់ទំនងលម្អិតទាំងនោះ បានធ្វើឡើងមុនការអះអាងរបស់ខ្លួនថា “ការយោងតែទៅលើឈ្មោះនិងមុខងារដែលបានលើកឡើងក្នុងអំឡុងពេលនៃការស៊ើបអង្កេត គឺជាមូលដ្ឋានមួយដ៏ចង្អៀតសម្រាប់វាយតម្លៃថាតើត្រូវស្តាប់ចម្លើយបុគ្គលនោះ ឬយ៉ាងណាទេនោះ”[៣៧]។ អង្គបុរេជំនុំជម្រះយល់ស្របទៅនឹងការអះអាងនេះដល់កម្រិតមួយដែលថា ការយោងតែទៅលើឈ្មោះ និងមុខងារទូទៅរបស់បុគ្គលនៅក្នុង ឬនៅក្រោមការគ្រប់គ្រងរបស់ក្រសួងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនបង្កើតឱ្យមានហេតុផល *បឋម* (*prima facie*) ដើម្បីឱ្យជឿបានថាបុគ្គលនោះអាចមានភស្តុតាង ឬព័ត៌មានដោះបន្ទុក ដែលមានភាពពាក់ព័ន្ធដល់ការបង្ហាញការពិត។ ការយោងទៅលើការគ្មានព័ត៌មានទំនាក់ទំនងលម្អិតមុនការអះអាង របស់សហចៅក្រមស៊ើបអង្កេតនេះ ទំនងធ្វើឡើងគ្រាន់តែគូសបញ្ជាក់ពីចេតនាចង់បានព័ត៌មានទាក់ទងនឹង [redacted] ដែលផ្តល់ឱ្យដោយដើមបណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ។

**ដំណាក់កាលស៊ើបអង្កេតនាពេលបច្ចុប្បន្ន**

---

[៣៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤០-៤១។

[៣៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤១។

[៣៧] ដីកាសម្រេច កថាខណ្ឌ ៣។

៣៥. ដើមបណ្ដឹងឧទ្ធរណ៍លើកឡើងដូចខាងក្រោម ទាក់ទងទៅនឹងសំអាងហេតុបន្ទាប់ទៀត របស់សហចៅក្រមស៊ើបអង្កេត៖

ក.ស.ច.ស មានការយល់ឃើញមិនបានត្រឹមត្រូវចំពោះ "ដំណាក់កាលស៊ើបអង្កេតនាពេលបច្ចុប្បន្ន" នៅពេលវាយតម្លៃថាតើ[redacted]នោះ អាចជួយដល់ការលាតត្រដាងការពិត ឬទេ... មេធាវីការពារក្ដីសូមអះអាងថា មធ្យោបាយតែមួយដែលដំណាក់កាលនៃការស៊ើបសួរអាចមានឥទ្ធិពលទៅលើ ក.ស.ច.ស នៅពេលធ្វើការសម្រេចចិត្តថាតើត្រូវស្ដាប់ចម្លើយបុគ្គលមួយចំនួន ឬទេនោះគឺ ក.ស.ច.ស បានប្រមូលភស្ដុតាងដែលមាននៅក្នុងសំណុំរឿងបច្ចុប្បន្ន ហើយភស្ដុតាងដែលស្នើឡើងដោយមេធាវីការពារក្ដី នឹងដូចគ្នាទៅនឹងព័ត៌មានដែលមាននៅក្នុងសំណុំរឿងរួចហើយ ឬក៏យ៉ាងណា។ ប៉ុន្ដែករណីនេះ វាមិនមែនបែបនេះទេ។ ក.ស.ច.ស គ្រាន់តែបានស្ដាប់ចម្លើយ បុគ្គលតែមួយចំនួនតូចប៉ុណ្ណោះ ដែលធ្លាប់បានបំពេញការងារនៅក្នុងក្រសួងសង្គមកិច្ច ក្នុងពេលវេលាដែលមានការពាក់ព័ន្ធ ហេតុដូច្នេះពួកគាត់មានភស្ដុតាងពាក់ព័ន្ធនឹងបញ្ហានេះតិចតួចណាស់[៣៨]។

៣៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដើមបណ្ដឹងឧទ្ធរណ៍មិនបានដកស្រង់សំអាងហេតុគាំទ្រការអះអាងរបស់ខ្លួនដែលថាសហចៅក្រមស៊ើបអង្កេត "ពិចារណាមិនត្រឹមត្រូវទៅលើ'ដំណាក់កាលស៊ើបសួរនាពេលបច្ចុប្បន្ន' ឬគាំទ្រការអះអាងរបស់ខ្លួន ដែលថា មានកាលៈទេសៈតែមួយគត់ដែលសហចៅក្រមស៊ើបអង្កេតអាចពិចារណា"យ៉ាងសមស្រប" ទៅលើដំណាក់កាលស៊ើបសួរបច្ចុប្បន្ន ដើម្បីសម្រេចបដិសេធសំណើសុំ ដោយអនុលោមតាមវិធាន ៥៥(១០)។ អង្គបុរេជំនុំជម្រះយល់ស្របជាមួយដើមបណ្ដឹងឧទ្ធរណ៍ក្នុងកម្រិតមួយដែលថា សហចៅក្រមស៊ើបអង្កេតមិនអាចបដិសេធសំណើសុំណាមួយ ដោយផ្អែកជាចម្បងទៅលើវិធាន ៥៥(១០) ឬផ្អែកលើវិធាននេះតែមួយគត់ ដោយសារកិច្ចស៊ើបសួរស្ថិតនៅក្នុងដំណាក់កាលចុងក្រោយនោះទេ[៣៩]។ ប៉ុន្ដែករណីនេះមិនមែនជាករណីរបស់បណ្ដឹងឧទ្ធរណ៍មួយនេះឡើយ។ សហចៅក្រមស៊ើបអង្កេតអាចផ្អែកជាផ្នែកទៅលើដំណាក់កាលស៊ើបសួរចុងក្រោយ រួមជាមួយហេតុផលដែលមានសុពលភាពផ្សេងៗទៀត ដើម្បីសម្រេចបដិសេធសំណើសុំណាមួយ។

**ភស្ដុតាងដែលពឹងថាអាចទទួលបាន**

---

[៣៨] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៥៤។

[៣៩] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្ដុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារលេខ D164/4/13 កថាខណ្ឌ ៣៦-៣៨។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

៣៧. ដើមបណ្តឹងឧទ្ធរណ៍អះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុស ដោយសារនៅក្នុងដីកាសម្រេចរបស់ខ្លួន សហចៅក្រមផ្អែកមួយផ្អែកទៅលើមូលហេតុដែលថា សំណើសុំនេះមិនបានផ្តល់ឱ្យនូវ "ការបង្ហាញណាមួយពីភស្តុតាងដែលរំពឹងថា អាចទទួលបានពីបុគ្គលណាមួយក្នុងចំណោម [redacted] នេះ"ទេ[៤០]។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា "មិនមានចំណុចណាមួយ ដែល ក.ស.ច.ស ឬអ.ប.ជ តម្រូវឱ្យសំណើសុំបំពេញកិច្ចស៊ើបសួរត្រូវបង្ហាញពី 'ភស្តុតាងដែលរំពឹងថាអាចទទួលបាន'ពីកិច្ចស៊ើបសួរនោះ។ ផ្ទុយទៅវិញ សំណើសុំត្រូវបង្ហាញពី 'ព័ត៌មានដែលស្នើឡើង' ដែលជាលក្ខខណ្ឌទាប និងខុសពី នេះមួយផ្សេងទៀត។ ហេតុដូច្នេះ ក.ស.ច.ស បានអនុវត្តលក្ខខណ្ឌមិនត្រឹមត្រូវ..."[៤១]។

៣៨. អង្គបុរេជំនុំជម្រះសូមរំលឹកថា បទដ្ឋានដែលសហចៅក្រមស៊ើបអង្កេតត្រូវគោរពយកមកអនុវត្តដើម្បីសម្រេចលើសំណើសុំ ដោយអនុលោមតាមវិធាន៥៥(១០)នោះ គឺត្រូវពិនិត្យមើល ថាតើដើមបណ្តឹងឧទ្ធរណ៍បានបង្ហាញហេតុផល *បឋម* សម្រាប់ឱ្យសហចៅក្រមស៊ើបអង្កេតជឿជាក់ថា បុគ្គលណាមួយ ឬច្រើន ក្នុងចំណោម [redacted] នេះ មានព័ត៌មានពាក់ព័ន្ធដែលអាចលាតត្រដាងការពិត ដែរឬទេ[៤២]។

៣៩. សហចៅក្រមស៊ើបអង្កេតយល់ច្បាស់ពីលក្ខណៈនៃបរិបទអ.វ.ត.ក ហើយជាញឹកញាប់រំលឹកដល់ភាគីពីលក្ខណៈនេះដែលភាគីមិនអាចស្តាប់ចម្លើយពីបុគ្គលដែលខ្លួនស្នើសុំឱ្យកោះហៅ ធ្វើជាសាក្សីបាន[៤៣]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា វាមិនទំនងទេដែលថា សហចៅក្រមស៊ើបអង្កេតប្រើឃ្លា "ភស្តុតាងដែលរំពឹងថាអាចទទួលបាន" ក្នុងន័យថា ដើមបណ្តឹងឧទ្ធរណ៍ត្រូវគោរពតាមវិធាន៥៥(១០) ក្នុងការផ្តល់ឱ្យសហចៅក្រមស៊ើបអង្កេតនូវការរំពឹងរបស់ខ្លួនទៅលើអ្វីដែល [redacted] នោះអាចនឹងនិយាយ ប្រសិនបើពួកគេត្រូវបានសម្ភាសន៍ ដោយ

---

[៤០] ដីកាសម្រេច កថាខណ្ឌ ៣។

[៤១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៧។

[៤២] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារលេខ D164/4/13 កថាខណ្ឌ ៣៦, ៤៥។

[៤៣] ជាអាទិ៍ [redacted]

សហចៅក្រមស៊ើបអង្កេត។ បរិបទនេះបបង្ហាញយ៉ាងច្បាស់ថា សហចៅក្រមស៊ើបអង្កេតបានប្រើឃ្លា "ភស្តុតាងដែលរំពឹងថាអាចទទួលបាន" ក្នុងន័យមួយថា បើតាមព័ត៌មានដែលខ្លួនមានដើមបណ្ដឹងឧទ្ធរណ៍គួរបានកំណត់ចំណុចនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលខ្លួនមានហេតុផលជឿជាក់ថា [redacted]នេះអាចផ្ដល់សក្ខីកម្ម ហើយនឹងផ្ដល់នូវមូលដ្ឋាននៃការជឿជាក់បែបនេះ។

៤០. [redacted]នេះត្រូវបានចោទប្រកាន់ថា បានបម្រើការងារក្រោមការគ្រប់គ្រងរបស់ក្រសួង។ ប៉ុន្តែ នៅក្នុងសំណើសុំ ដើមបណ្ដឹងឧទ្ធរណ៍មិនបានផ្ដល់ឱ្យនូវការដឹងឮជាក់លាក់របស់ខ្លួនពីមូលហេតុដែលថា បុគ្គលជាក់លាក់ទាំងនេះ "មានលទ្ធភាពផ្ដល់ឱ្យក.ស.ច.ស នូវព័ត៌មានពាក់ព័ន្ធ"[៤៤]។ ទាក់ទងនឹងបញ្ហានេះ សហចៅក្រមស៊ើបអង្កេតមិនមានកំហុសនោះទេ ដោយផ្អែកមួយផ្នែកទៅលើអង្គហេតុដែលថា ដើមបណ្ដឹងឧទ្ធរណ៍មិនបានផ្ដល់ឱ្យនូវ "ភស្តុតាងដែលរំពឹងថាអាចទទួលបាន" ពីបុគ្គលទាំងនោះ។

**មុខងារតូចតាចនៅក្នុងក្រសួង**

៤១. ដើមបណ្ដឹងឧទ្ធរណ៍អះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់ ដោយបានផ្អែកទៅលើកត្តាមុខងារ"តូចតាច"[៤៥] របស់[redacted] ដើម្បីបដិសេធសំណើសុំនេះ[៤៦]។ ដើមបណ្ដឹងឧទ្ធរណ៍"សង្កត់ធ្ងន់ថាមុខងារពីមុនរបស់[redacted]នេះមិនគួរជាកត្តាសម្រេច"[៤៧] សម្រាប់ឱ្យសហចៅក្រមស៊ើបអង្កេតផ្អែកលើ ដើម្បីសម្រេចលើសំណើសុំណាមួយ ដោយអនុលោមតាមវិធាន ៥៥(១០) នោះទេ។ ការអានដីកាសម្រេចនេះ ដោយពិចារណាទៅលើបរិបទបង្ហាញថា មុខងារតូចតាចរបស់[redacted]នេះមិនចាំបាច់ជាកត្តា "សម្រេច"របស់សហចៅក្រមស៊ើបអង្កេតឡើយ។ បើទោះជាមុខងារតូចតាចរបស់[redacted]នេះ គឺជាកត្តា

[៤៤] សំណើសុំ កថាខណ្ឌ ១៥-១៦។

[៤៥] ដីកាសម្រេច កថាខណ្ឌ ៤។ បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៥២។

[៤៦] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៥២។

[៤៧] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៥៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE C.C.C * C.E.

00531890



“សម្រេច”របស់សហចៅក្រមស៊ើបអង្កេតក៏ដោយ ក៏អង្គបុរេជំនុំជម្រះពិចារណាឃើញថា ករណីនេះមិនបង្កើតបានជា ការអនុវត្តឆន្ទានុសិទ្ធិមិនសមស្របនោះដែរ។

៤២. ជាពិសេស នេះមិនមែនជាការអនុវត្តឆន្ទានុសិទ្ធិមិនសមស្របនោះទេ ដែលសហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា នៅពេលដែលគ្មានហេតុផល *បបម* ដើម្បីសម្រេចឲ្យផ្ទុយពីនេះ បុគ្គលណាមួយដែលមានមុខងារតូចតាចនៅក្នុងក្រសួង “មិនទំនងជាអាចផ្តល់ឲ្យនូវព័ត៌មានលម្អិតគ្រប់គ្រាន់” ស្តីអំពីតួនាទី និងការទទួលខុសត្រូវរបស់ដើមបណ្តឹងឧទ្ធរណ៍ ក្នុងអំឡុងពេលខ្លួនធ្វើជារដ្ឋមន្ត្រី ឬស្តីអំពី“លទ្ធភាពរបស់ដើមបណ្តឹងឧទ្ធរណ៍ក្នុងការ ទទួលបាននូវព័ត៌មានលម្អិតពីព្រឹត្តិការណ៍ដែលកើតឡើងក្នុងអំឡុងពេលវេលាពាក់ព័ន្ធនៅ ពេលខ្លួនដើរតួនាទីជារដ្ឋមន្ត្រី”ទេ។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា មុខងារពីមុនរបស់បុគ្គលណាមួយ “មិនចាំបាច់ថាមានភាពពាក់ព័ន្ធ”ទេ[៤៨]។ ការប្រើប្រាស់ពាក្យពេចន៍ដោយដើមបណ្តឹងឧទ្ធរណ៍បែបនេះ អាចឲ្យយល់បានថា ដើមបណ្តឹងឧទ្ធរណ៍យល់ស្របថា ការផ្តែកមួយផ្នែកទៅលើមុខងារតូចតាចរបស់បុគ្គលណាមួយ អាចមានភាពពាក់ព័ន្ធទៅតាមកាលៈទេសៈមួយចំនួន។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា បណ្តឹងឧទ្ធរណ៍នេះស្ថិតនៅក្នុងកាលៈទេសៈមួយក្នុងចំណោមកាលៈទេសៈទាំងនោះ។

៤៣. ទាក់ទងទៅនឹងបុគ្គលមួយក្នុងចំណោម [redacted] នេះដែលត្រូវបានចោទប្រកាន់ថា [redacted] របស់ដើមបណ្តឹងឧទ្ធរណ៍ ក្នុងអំឡុងពេលមិនជាក់លាក់មួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អង្គបុរេជំនុំជម្រះពិចារណាឃើញដូចដើមបណ្តឹងឧទ្ធរណ៍ទំនងជាលើកឡើងថា តួនាទីមួយនេះ បើតាមស្ថានភាពជាក់ស្តែង (*ipso facto*) មិនបង្កើតឲ្យបានជាមូលដ្ឋាន *បបម* មួយថា បុគ្គលនោះមានព័ត៌មានដែលអាចជួយលាតត្រដាងការពិតបានទេ។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការសម្រេចបែបនេះស្ថិតនៅក្នុងអំណាចឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការបដិសេធសំណើសុំស្តាប់ចម្លើយពីបុគ្គលណាមួយ ដោយហេតុថា ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់ព័ត៌មានផ្សេងទៀតអំពីបុគ្គលរូបនោះ ដែលអាចបង្ហាញពីហេតុផល *បបម* ដើម្បីទទួលយកសំណើសុំបាន។

## សំអាងហេតុចំពោះមូលដ្ឋានទីពីររបស់បណ្តឹងឧទ្ធរណ៍

[៤៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥២។

៤៤. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតធ្វើឡើងដោយផ្អែកទៅលើមូលហេតុដែលមានសុពលភាពចំនួនពីរ៖ (១) មុខងារតូចតាចរបស់[redacted]ទៅក្នុងក្រសួង និង(២) ការគ្មានព័ត៌មានផ្សេងទៀតស្តីពីបុគ្គល ទាំងនោះដែលអាចបង្កើតឱ្យមានមូលដ្ឋាន *បឋម* ណាមួយ ដើម្បីឱ្យសហចៅក្រមស៊ើប អង្កេតជឿជាក់ថា បុគ្គលម្នាក់ ឬច្រើនក្នុងចំណោមបុគ្គលទាំងនោះ មានព័ត៌មានដែលអាចជួយលាតត្រដាងការពិតបាន។ អង្គបុរេជំនុំជម្រះយល់ឃើញថា មិនមានការអនុវត្តឆន្ទានុសិទ្ធិមិនសមស្រប ដោយសហចៅក្រមស៊ើបអង្កេតនោះទេ ក្នុងការសម្រេចបដិសេធសំណើ ដោយផ្អែកតែទៅលើមូលហេតុចំនួនពីរនេះ។

**មូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍ ÷ ការរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះក្តី ដោយយុត្តិធម៌មួយ**

៤៥. ដើមបណ្តឹងឧទ្ធរណ៍អះអាងថា ដីកាសម្រេច "មិនមានយុត្តិធម៌ដែលបង្កើតបានជាការរំលោភបំពានចំពោះឆន្ទានុសិទ្ធិរបស់ ក.ស.ច.ស។ ដោយបដិសេធមិនស៊ើបអង្កេតលើ ភស្តុតាងដោះបន្ទុក ក.ស.ច.ស បានរំលោភបំពានលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌មួយ"[៤៩]។ អង្គបុរេជំនុំជម្រះយល់ស្របថា បើសិនជាដូច្នេះមែន នេះអាចបង្កើតបានជាការបកស្រាយមិនត្រឹមត្រូវទៅលើច្បាប់ជាធរមាន ដែលជាការសន្និដ្ឋានទៅលើអង្គហេតុមិនត្រឹមត្រូវទាល់តែសោះ និង/ឬ ជាការរំលោភបំពានអំណាចឆន្ទានុសិទ្ធិ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ករណីនោះក្នុងបណ្តឹងឧទ្ធរណ៍នេះមិនដូច្នោះទេ។

៤៦. ដើមបណ្តឹងឧទ្ធរណ៍លើកឡើងត្រឹមត្រូវដែលថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ច ក្នុងការស៊ើបអង្កេតភស្តុតាងដោះបន្ទុក[៥០]។ ប៉ុន្តែ ដើមបណ្តឹងឧទ្ធរណ៍បង្កើតបទដ្ឋានក្នុងការបង្ហាញភស្តុតាងមិនត្រឹមត្រូវ ដូចដែលបានចែងនៅក្នុងវិធាន៥៥(១០) ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេតជឿជាក់ថា កិច្ចស៊ើបសួរនោះអាចបង្កើតឱ្យមានភស្តុតាងដោះបន្ទុកបាន។

៤៧. បទដ្ឋានពិនិត្យភស្តុតាងដ៏ត្រឹមត្រូវនោះទាមទារឱ្យដើមបណ្តឹងឧទ្ធរណ៍បានបង្ហាញហេតុផល *បឋម* សម្រាប់ឱ្យសហចៅក្រមស៊ើបអង្កេតជឿជាក់ថា បុគ្គលមួយ ឬច្រើន ក្នុងចំណោម[redacted]

---

[៤៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៨។

[៥០] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារលេខ D164/4/13 កថាខណ្ឌ ៣៦។

[redacted]នេះ អាចមានភស្តុតាងដោះបន្ទុក ដែរឬទេ[៥១]។ ដើមបណ្តឹងឧទ្ធរណ៍បង្កើតបទដ្ឋានមិនត្រឹមត្រូវដូចតទៅ៖ "បន្ទាប់ពីមេធាវីការពារក្តីបានស្រាវជ្រាវបឋមរួចហើយ ដែលនាំឱ្យមេធាវីការពារក្តីជឿជាក់ដោយសមហេតុផលថា បុគ្គលទាំងនោះអាចមានព័ត៌មាដោះបន្ទុក ហើយព័ត៌មានទាំងនោះមិនមែនជាផ្នែកមួយនៃព័ត៌មាននៅក្នុងសំណុំរឿងទេ ក.ស.ច.ស មានកាតព្វកិច្ចបន្តការស៊ើបអង្កេតលើរឿងនេះ"[៥២]។ ការបង្កើតបទដ្ឋានមិនត្រឹមត្រូវនេះបញ្ជាក់ថា កត្តាសម្រេចនោះគឺមើលទៅលើ ថាតើដើមបណ្តឹងឧទ្ធរណ៍ "ជឿជាក់ដោយសមហេតុផលថា បុគ្គលទាំងនោះអាចមានព័ត៌មានដោះបន្ទុកឬទេ"។ មិនថាដើមបណ្តឹងឧទ្ធរណ៍ជឿជាក់ខ្លាំងប៉ុណ្ណាទៅលើខ្លឹមសារនៃសំណើរបស់ខ្លួន កត្តាសម្រេចនោះគឺថា តើសហចៅក្រមស៊ើបអង្កេតជឿជាក់ថា ដើមបណ្តឹងឧទ្ធរណ៍បានបង្ហាញនូវហេតុផល *បឋម* សម្រាប់ឱ្យសហចៅក្រមស៊ើបអង្កេតជឿជាក់ថា កិច្ចស៊ើបសួរនោះអាចបង្កើតបាននូវភស្តុតាងដោះបន្ទុកដែរឬទេ។

៤៨. ដើមបណ្តឹងឧទ្ធរណ៍អះអាងថា សហចៅក្រមស៊ើបអង្កេតគួរបានអនុវត្តបទដ្ឋានដូចខាងក្រោម ដូចដែលបានទទួលស្គាល់ដោយអង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាវ៉ាន់ដា("ICTR") ដើម្បីវាយតម្លៃ ថាតើបុគ្គលម្នាក់ ឬច្រើន ក្នុងចំណោម[redacted]នេះ មានភស្តុតាងដោះបន្ទុកដែរឬទេ[៥៣]៖

> ដើម្បីដឹងបានថាតើព័ត៌មាន "អាចបញ្ជាក់ពីភាពគ្មានពិរុទ្ធភាព ឬអាចសម្រាលពិរុទ្ធភាពរបស់ជនត្រូវចោទ" គេត្រូវផ្អែកទៅលើការវាយតម្លៃថាតើព័ត៌មាននោះ ដោយផ្អែកទៅលើសារណារបស់ភាគី អាចមានភាពពាក់ព័ន្ធសម្រាប់ការការពារក្តីរបស់ជនត្រូវចោទ ដែរឬទេ[៥៤]។

៤៩. ដើមបណ្តឹងឧទ្ធរណ៍លើកឡើងត្រឹមត្រូវដែលថា អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃ ICTR ទទួលស្គាល់លក្ខខណ្ឌនេះថាជា "បទដ្ឋានត្រឹមត្រូវសម្រាប់វាយតម្លៃថាតើសម្ភារៈជាក់លាក់ណាមួយត្រូវ

---

[៥១] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារលេខ D164/4/13 កថាខណ្ឌ ៣៦។

[៥២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៤។

[៥៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៤។

[៥៤] *រដ្ឋអាជ្ញា តទល់នឹង Karemera នឹងអ្នកដទៃទៀត* ICTR-98-44-AR73.33 "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Joseph Nzirorera ប្រឆាំងនឹងសេចក្តីសម្រេចលើពាក្យសុំតាមវិធាន ៦៨ លើកទីដប់" អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៨ ("*Karemera*") កថាខណ្ឌ ១២។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

បានចាត់ទុកថាដោះបន្ទុក ទៅតាមអត្ថន័យនៃវិធាន ៦៨(ក) នៃវិធានICTR”ដែរឬទេ[៥៥]។ ប៉ុន្តែ តាមសំអាងហេតុសម្រាប់សេចក្តីសម្រេចនេះ បានបង្ហាញយ៉ាងច្បាស់ថា អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នេះ បានចាត់ទុកបទដ្ឋាននេះថាមានលក្ខណៈស្របគ្នាជាមួយនឹង ហើយមិនទាបជាងលក្ខខណ្ឌក្នុងការបង្ហាញ “ហេតុផល *បឋម* ដែល បញ្ជាក់ពីលក្ខណៈដោះបន្ទុកដែលអាចមានពីសម្ភារៈនោះ”[៥៦]។

៥០. ដើមបណ្តឹងឧទ្ធរណ៍អះអាងដោយគ្មានការគាំទ្រថា “មេធាវីការពារក្តីបានផ្តល់ឱ្យនូវភស្តុតាងបឋមដែលថា [redacted] នោះ អាចមានព័ត៌មានដោះបន្ទុកដែលមិនមាននៅក្នុងសំណុំរឿង”[៥៧]។ ដោយហេតុថា ដើមបណ្តឹងឧទ្ធរណ៍ពិតជាបានផ្តល់ឱ្យតែឈ្មោះ និងមុខងារទូទៅរបស់បុគ្គលទាំងនោះនៅក្នុងក្រសួង អង្គបុរេជំនុំជម្រះពិចារណាឃើញថា សហចៅក្រមស៊ើបអង្កេតមិនបានអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនដោយមិនសមស្របនោះទេ ក្នុងការសន្និដ្ឋានថា ដើមបណ្តឹងឧទ្ធរណ៍មិនបានបំពេញលក្ខខណ្ឌ *បឋម* នោះ។

៥១. ហេតុដូច្នេះ មូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធចោល។

## ការចោទប្រកាន់ពីភាពលំអៀងរបស់សហចៅក្រមស៊ើបអង្កេត

៥២. នៅក្នុងបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងឧទ្ធរណ៍ចោទប្រកាន់ថា ដីកាសម្រេច “នាំឱ្យមានការចោទសួរទៅលើអនាគតភាពរបស់ក.ស.ច.ស” ហើយថា សហចៅក្រមស៊ើបអង្កេត“យកចិត្តទុកដាក់ប្រមូលភស្តុតាងដាក់បន្ទុកប្រឆាំងនឹងជនត្រូវចោទ ច្រើនជាងការប្រមូលភស្តុតាងដោះបន្ទុក”[៥៨]។ ដើមបណ្តឹងឧទ្ធរណ៍ និងសហមេធាវីការពារក្តីរបស់ខ្លួនព្យាយាម“គាំទ្រ” ការចោទប្រកាន់ធ្ងន់ធ្ងរបែបនេះដោយយោងទៅលើ និងដកស្រង់ពីសំណើមួយ អនុលោមតាមវិធាន ៣៤(២) ដែលនឹងត្រូវ

---

[៥៥] *Karemera* កថាខណ្ឌ ១២។

[៥៦] *Karemera* កថាខណ្ឌ ៩, ១៤។

[៥៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៦។

[៥៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៦-៦៧។

ដោះស្រាយឆាប់ៗខាងមុខ[៥៩]។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា វិធីសាស្ត្រនេះ មិនមានភាពសមស្របយ៉ាងខ្លាំង។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

(១) ទទួលយកបណ្តឹងឧទ្ធរណ៍នេះ តាមទម្រង់។

(២) ទទួលយកដោយផ្នែក (កថាខណ្ឌ ២៩-៣១ ខាងលើ) ចាត់ទុកថាបានការ។

(៣) ច្រានចោលផ្នែកដទៃទៀតនៃបណ្តឹងឧទ្ធរណ៍នេះ ចាត់ទុកថាឥតបានការ។

**ភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០**

**ចៅក្រមអង្គបុរេជំនុំជម្រះ**

Rowan DOWNING **ន័យ ថុល** Catherine MARCHI-UHEL **ហួត វុទ្ធី** **ប្រាក់ គឹមសាន**

---

[៥៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៧។

*សាលដីកាលើបណ្តឹងឧទ្ធរណ៍សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ២៧ របស់សហមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០*